## "បានមករស់នៅលើដីថ្មីនេះ ដូចខ្ញុំបានកើតម្តងទៀតអីចឹង!"

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ គឺជាសមាសធាតុសំខាន់មួយរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំហាន២ (LASED II) ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២១ នៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចទាំង១៨កន្លែង នៅក្នុងខេត្តគោលដៅទាំង៥ រួមមានខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ ត្បូងឃ្មុំ និងក្រចេះ ដែលអនុវត្តគម្រោង LASED II។ ជាក់ស្តែង សម្បទានិកចំនួន៧៧៦គ្រួសារ ដែលទទួលបានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុ កាលពីខែមីនា ឆ្នាំ២០១៨ បាននឹងកំពុងរស់នៅអាស្រ័យផលលើដីសម្បទានសង្គមកិច្ច ដែលពួកគាត់បានទទួល ស្ថិតក្នុងឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ កំពុងទទួលបានផលប្រយោជន៍យ៉ាងច្រើនពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានា របស់គម្រោង។



លោក ប៉ែន តូ សមាជិកក្រុមប្រឹក្សាឃុំទីពោ

*"អត់ផ្លូវ ដូចយកពលរដ្ឋទៅទុកចោលក្នុងព្រៃអីចឹង"* នេះជាការលើកឡើងរបស់លោក ប៉ែន តូ ដែលជាសមាជិកក្រុមប្រឹក្សាឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលកាលពីមុនលោកជាប្រជាពលរដ្ឋក្រីក្រ និងគ្មានដីនៅឃុំពីពោ បន្ទាប់មកលោកត្រូវបានជ្រើសរើសជាសម្បទានិកនៅឃុំទីពោតំបន់១ និងធ្លាប់ជួយសម្របសម្រួលការងារគម្រោង LASED នៅដំណាក់កាលសាកល្បងដែលមានតួនាទីជាជំនួយការស្មៀនឃុំ។ លោក ប៉ែន តូ បានរៀបរាប់ទាំងទឹកមុខស្ងួតថា *"កាលពីមិនទាន់មានគម្រោង LASED ផ្លូវចូលទៅកាន់ទីតាំងដីនោះតូច ចូលតែរទេះគោមួយស្មើរតែមិនរួច ហើយការធ្វើដំណើរក៏ចំណាយពេលយូរដែរ ពេលខ្លះត្រូវដេកពាក់កណ្តាលផ្លូវក៏មាន តែពេលនេះ ទៅមកទីនោះ យើងមិនបាច់ដេកផ្លូវទេ"*។ លោកកំពុងនិយាយពីផ្លូវមេគ្រួសក្រហមមួយខ្សែប្រវែងជាង១១គីឡូម៉ែត្រ ដែលស្ថាបនាដោយគម្រោង LASED II ដែលតភ្ជាប់ពីផ្លូវគ្រួសក្រហមរបស់ឃុំទីពោ ចូលទៅទីតាំងដីសម្បទានសង្គមកិច្ច។ លោកបានបន្ថែមថា ផ្លូវនេះមិនត្រឹមតែបម្រើឱ្យការធ្វើដំណើររបស់ប្រជាពលរដ្ឋទៅកាន់ទីតាំងដីសម្បទានសង្គមកិច្ចប៉ុណ្ណោះទេ ថែមទាំងជាផ្លូវដែលតភ្ជាប់ទៅឃុំផ្សេងៗទៀត ហើយវាក៏បម្រើជាប្រយោជន៍ដល់ប្រជាពលរដ្ឋទូទៅផងដែរ។ លោកបន្ថែមថា *"ផ្លូវមេគ្រួសក្រហមនេះ ជាផ្លូវសម្រាប់ដឹកកសិផល ដឹកបញ្ជូនអ្នកជំងឺ ឬស្ត្រីមានផ្ទៃពោះទៅមណ្ឌលសុខភាព និងងាយស្រួលក្នុងការធ្វើទំនាក់ទំនងគ្នាទៅវិញទៅមក"*។




ផ្លូវមេគ្រួសក្រហមចូលទៅទីតាំងដីសង្គមកិច្ច



**លោកស្រី ឈឹម សុខឡូននិងជីវិតថ្មីលើដីសង្គមកិច្ច**

*"បានមករស់នៅលើដីថ្មីនេះ ដូចខ្ញុំបានកើតម្តងទៀតអីចឹង!"* នេះជាការលើកឡើងរបស់លោកស្រី ឈឹម សុខឡូន ដែលជាសម្បទានិករស់នៅក្នុងភូមិសែនអភិវឌ្ឍន៍១ ឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ។ លោកស្រីបានទទួលស្គាល់ថា ការអភិវឌ្ឍផ្លូវមេត្រីស្រូវក្រហមមួយខ្សែនេះ ពិតជាបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់សម្បទានិកទាំងអស់។ លោកស្រីបានលើកឡើងថា *"បើអត់មានផ្លូវវាលំបាក ពេលឈឺថ្កាត់យប់ព្រលប់អីអីចឹង ពិបាកណាស់ ពិបាកធ្វើដំណើរ។ ពេលឥឡូវបានផ្លូវស្រួល គ្រាន់យើងឈឺថ្កាត់អីទៅ [មណ្ឌលសុខភាព] ផ្លូវស្រួល ហើយស្រួលទៅផ្សារទៅអីគ្រាន់ស្រួលទិញសម្ភារៈប្រើប្រាស់"*។



**លោក ជឹក ជន លក់ដូរនៅផ្ទះបន្ថែមលើការបង្កបង្កើនផល និងចិញ្ចឹមសត្វ**

ក្នុងវ័យ៤១ឆ្នាំ លោក ជឹក ជន ធ្លាប់ជាប្រជាពលរដ្ឋសាមញ្ញ កាលរស់នៅភូមិចាស់នៅឯភូមិស្រែស្រម៉ ក្នុងឃុំទីពោ បន្ទាប់ពីលោកបានផ្លាស់ប្តូរទីលំនៅមករស់នៅលើដីសម្បទានសង្គមកិច្ច ដែលរាជរដ្ឋាភិបាលបានចែកជូន លោកត្រូវបានជ្រើសរើសជាមេភូមិសែនអភិវឌ្ឍន៍១ ឃុំទីពោ ស្រុកសន្ទុក។ លោកបានទទួលស្គាល់ថា *"កាលពីមុនផ្លូវលំបាក តែទៅហើយមិនចង់មកវិញទេ តែបើមកដល់ហើយ មិនចង់ទៅវិញដែរ។ តែឥឡូវផ្លូវស្រួលហើយ។ បានផ្លូវស្រួលយើងស្រួលទៅមកបានលឿន"*។

ទាំងលោកស្រី ឈឹម សុខឡូន ទាំងលោក ជឹក ជន បានលើកឡើងដូចគ្នាថា ជីវភាពរបស់ពួកគាត់កាន់តែប្រសើរឡើង តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា ជាពិសេសផ្លូវមេត្រីស្រូវក្រហមនេះ។ អ្នកទាំងពីរលើកឡើងថា កាលពីមុន ទោះបីជាពួកគាត់ដាំដុះកសិផលបាន ឬចិញ្ចឹមសត្វបានសម្រាប់លក់ដូរ ក៏គ្មានឈ្មួញចូលទៅទិញដែរ ព្រោះផ្លូវលំបាកពេក ប៉ុន្តែបន្ទាប់ពីគម្រោងបានស្ថាបនាផ្លូវមេត្រីស្រូវក្រហមនេះរួចមក ឈ្មួញបានចូលទៅទិញកសិផល និងសត្វចិញ្ចឹមផ្សេងៗរបស់សម្បទានិកដល់ផ្ទះតែម្តង ដែលធ្វើឱ្យសម្បទានិកងាយស្រួលលក់ដូរ និងបង្កើនជីវភាពរបស់ខ្លួន។ តាមរយៈផ្លូវមេត្រីស្រូវក្រហមមួយខ្សែនេះ លោក ប៉ែន តូ មានប្រសាសន៍បន្ថែមថា *"ខ្ញុំគិតថា*



**ការដឹកជញ្ជូនរបស់សម្បទានិកតាមផ្លូវមេត្រីស្រូវក្រហម**

*៧០ភាគរយនៃចំណូលរបស់ប្រជាពលរដ្ឋបានមកពីការប្រើប្រាស់ផ្លូវមេគ្រួសក្រហមនេះ"*។

នៅពេលគេធ្វើដំណើរតាមផ្លូវមេគ្រួសក្រហមនោះ ឆ្ពោះទៅកាន់ទីតាំងដីសម្បទានសង្គមកិច្ចក្នុងឃុំទីពោ គេនឹងឃើញសំណង់អគារហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀតដែលក្នុងនោះមានអគារសាលាបឋមសិក្សាផងដែរ។ តាមផែនការ គម្រោង LASED II បានសាងសង់អគារសាលាបឋមសិក្សាថ្មីចំនួន ១ខ្នងបន្ថែមទៀត ដើម្បីឱ្យកូនៗរបស់សម្បទានិកមានឱកាសបានចូលរៀនគ្រប់ៗគ្នា។ *"ការបង្កើតសាលាបឋមសិក្សានៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចនេះ មិនត្រឹមតែអាចឱ្យកូនៗរបស់សម្បទានិកចូលរៀនបានទេ កូនៗរបស់អ្នកភូមិដែលនៅជាប់នឹងដីសម្បទាននេះក៏អាចមកចូលរៀនបានដែរ"* នេះជាការលើកឡើងរបស់លោក ប៉ែន តូ។ តាមការសង្កេតកន្លង លោកមើលឃើញថា *"ឪពុកម្តាយភាគច្រើនបានឱ្យកូនៗរបស់ពួកគាត់ទៅសាលារៀន ព្រោះពួកគាត់គិតថា កាលណាកូនៗមានចំណេះដឹង ពួកគេនឹងចេះគិតវែងឆ្ងាយ មិនឆាប់ចាញ់តាមការបោកបញ្ឆោតរបស់អ្នកដទៃ អាចមានការងារធ្វើត្រឹមត្រូវ ចេះអភិវឌ្ឍខ្លួន និងធ្វើសេចក្តីសម្រេចចិត្តបានត្រឹមត្រូវ"*។ លោក ជឹក ជន បានគាំទ្រទៅនឹងការលើកឡើងរបស់លោក ប៉ែន តូ ថា *"បើគ្មានហេដ្ឋារចនាសម្ព័ន្ធទេ យើងមិនអាចរស់នៅបានទេ ដូចជាសាលារៀន បើគ្មានសាលារៀនកូនយើងមិនបានចូលរៀន ហើយបើយើងឱ្យកូនទៅរៀនឆ្ងាយ យើងបារម្ភពីគេ"*។


សាលាបឋមសិក្សាជាថ្នាលបណ្តុះចំណេះដល់កូនសម្បទានិក


ផ្លូវកាត់ខ្វាត់ខ្វែងចូលទៅលំនៅឋានសម្បទានិក

នៅពេលគេធ្វើដំណើរចូលទៅដល់ទីតាំងដីសម្បទានសង្គមកិច្ច គេឃើញមានផ្លូវដីស ឬផ្លូវគ្រួសក្រហមខ្វាត់ខ្វែង កាត់ទទឹងផ្លូវមេគ្រួសក្រហមចូលទៅកាន់លំនៅឋានរបស់សម្បទានិកដែលមើលទៅហាក់ដូចជាបុរីនៅជនបទដូច្នោះដែរ។ នៅទីនោះ ពួកគាត់បានទទួលដីលំនៅឋានទំហំ ៣០ x ៤០ ម៉ែត្រ និងបានសង់ផ្ទះទៅតាមលទ្ធភាពរបស់គ្រួសារនីមួយៗ។ ចំពោះដីដែលនៅសេសសល់ជុំវិញផ្ទះ ពួកគាត់បានដាំដើមផ្លែឈើហូបផ្លែ ដាំបន្លែផ្សេងៗ ហើយគ្រួសារមួយចំនួនបានធ្វើទ្រុងចិញ្ចឹមមាន់ ទា និងសត្វគោ ក្របីថែមទៀតផង។ ដើម្បីជួយសម្រួលដល់ការដាំបន្លែ


ការចិញ្ចឹមសត្វរបស់សម្បទានិក



អណ្តូងទឹកស្នប់ជួយសម្រួលដល់ការរស់នៅរបស់សម្បទានិក

និងចិញ្ចឹមសត្វរបស់ពួកគាត់ គម្រោង LASED II ក៏បានសាងសង់អណ្តូងទឹកស្នប់ នៅតាមលំនៅឋាន និងបានសាងសង់ប្រព័ន្ធធារាសាស្ត្រខ្នាតតូច និងអាងស្តុកទឹកនៅទីតាំងសំខាន់ៗមួយចំនួន ដើម្បីឱ្យពួកគាត់ប្រើប្រាស់ជាលក្ខណៈគ្រួសារ និងប្រើប្រាស់រួមផងដែរ។ លោក ប៉ែន តូ បានបន្តទៀតថា កាលពីមិនទាន់មានគម្រោង LASED II ប្រជាពលរដ្ឋដែលចូលទៅទីនោះប្រើប្រាស់តែទឹកអូរ ហើយអូរនោះ នៅឆ្ងាយពីកន្លែងដែលពួកគាត់រស់នៅដែលត្រូវចំណាយពេលច្រើនទៅដងទឹកពីអូរយកមកប្រើប្រាស់។ *"ពេលនេះគម្រោងបានជីកអណ្តូងស្នប់ ហើយប្រជាពលរដ្ឋក៏បានជីកអណ្តូងដាក់លូ ប្រើស្ទើរគ្រប់ផ្ទះ។ វាងាយស្រួលជាងមុន មិនចំណាយពេលទៅដងទឹកនៅតាមអូរ ទឹកស្អាតអាចប្រើប្រាស់បាន និងមានពេលវេលាទៅដាំដុះ និងធ្វើការងារផ្សេងៗ"* នេះជាការលើកឡើងរបស់លោក ប៉ែន តូ សមាជិកក្រុមប្រឹក្សាឃុំទីពោ។



ស្រះស្តុកទឹកស្អាតទុកសម្រាប់ប្រើប្រាស់នៅរដូវប្រាំង

ក្រៅពីហេដ្ឋារចនាសម្ព័ន្ធដែលបានរៀបរាប់ខាងលើ គម្រោង LASED II ក៏បានសាងសង់អគារសហគមន៍ សម្រាប់ប្រើប្រាស់នៅពេលប្រជុំ ឬរៀបចំពិធីផ្សេងៗ វត្តអារាមសម្រាប់សម្បទានិករៀបចំកម្មវិធីបុណ្យទាន ប៉ុស្តិ៍សុខភាព អគារស្នាក់នៅរបស់គ្រូបង្រៀន និងគិលានុបដ្ឋាកយិកា ដើម្បីឱ្យសម្បទានិកអាចពិនិត្យ និងទទួលថ្នាំព្យាបាលមួយចំនួន និងដើម្បីលើកទឹកចិត្តដល់គ្រូបង្រៀន និងគិលានុបដ្ឋាកឱ្យមកបំពេញការងារនៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចនេះឱ្យកាន់តែមានប្រសិទ្ធភាពផងដែរ។

តាមរយៈការផ្តល់ដីសម្បទានសង្គមកិច្ចជាដីលំនៅឋាន និងដីកសិកម្មជាលក្ខណៈគ្រួសារ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តគ្រប់បែបយ៉ាងនេះ សម្បទានិកដែលបានមករស់នៅទីនេះសុទ្ធតែបានសម្តែងក្តីរីករាយ និងបានបង្ហាញពីភាពរីកចម្រើនផ្នែកជីវភាពរស់នៅរបស់ពួកគាត់ផងដែរ។ លោកស្រី ឈឹម សុខឡូន និយាយទាំងទឹកមុខញញឹមថា កាលពីមុន *"ខ្ញុំគ្មានដីសម្រាប់សង់ផ្ទះទេ ហើយក៏គ្មានដីដាំដុះដំណាំផ្សេងៗដែរ។ ពេលមកនៅទីនេះ [ដីសម្បទានសង្គមកិច្ច] ខ្ញុំមានដីសង់ផ្ទះ មានដីធ្វើស្រែចម្ការ ហើយអាចរកស៊ីផ្សេងៗ ដើម្បីផ្គត់ផ្គង់ជីវភាពរាល់ថ្ងៃ*




ប៉ុស្តិ៍សុខភាពមានគិលានុបដ្ឋាកសម្រាប់ព្យាបាលសម្បទានិកពេលមានជំងឺ

បានទៀតផង"។ "ចំពោះជីវភាពវិញ មករស់នៅទីនេះ [ដីសម្បទានសង្គមកិច្ច] ខ្ញុំឃើញភាគច្រើនប្រជាពលរដ្ឋធូរធារច្រើនជាងរស់នៅទីនោះ [ភូមិចាស់] ឆ្ងាយណាស់"។ នេះជាការលើកឡើងរបស់លោក ជឹក ជន។ គាត់បានបន្ថែមថា "ពេលប្រជាពលរដ្ឋបានមករស់នៅទីនេះ គាត់ខំប្រឹងជាងមុនឆ្ងាយ ហើយគាត់រកបានចំណូលច្រើនជាងមុន។ កាលពីមុនគាត់ស៊ីឈ្នួលគេ តែពេលនេះគាត់លែងចង់ហើយ គឺគាត់ប្រឹងធ្វើ [ដាំដុះ] ដោយខ្លួនឯង"។ លោក ប៉ែន តូ សម្តែងអារម្មណ៍ថា "ខ្ញុំមានអារម្មណ៍រំភើប និងត្រេកអរណាស់ដែលឃើញប្រជាពលរដ្ឋរីកចម្រើន តាំងពីអត់ដី រហូតមានដី តាំងពីអត់មធ្យោបាយធ្វើដំណើរ រហូតមានម៉ូតូ មានគោយន្តសម្រាប់ប្រើប្រាស់ធ្វើឱ្យជីវភាពគ្រួសាររីកចម្រើន"៕



អគារសហគមន៍ជាកន្លែងប្រមូលផ្តុំសម្បទានិកពេលមានកម្មវិធីផ្សេងៗ



ជីវិតរបស់សម្បទានិកកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ